# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ប្រាក់បំណាច់ចំពោះសមាជិក

## ក្រុមប្រឹក្សាឃុំ សង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- យោងស្មារតីអង្គប្រជុំលើកទី១៤ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០២ តទៅ ប្រាក់បំណាច់ប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានកំណត់ដូចខាងក្រោម :

- ប្រធានក្រុមប្រឹក្សា និង ជាមេឃុំ ចៅសង្កាត់ ក្នុងមួយនាក់ ១០០.០០០ រៀល ក្នុងមួយខែ ។
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលមុខតំណែងជាជំទប់ទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ ក្នុងមួយនាក់ ៨០.០០០ រៀល ក្នុងមួយខែ ។
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនស្ថិតក្នុងមុខតំណែងខាងលើក្នុងមួយនាក់ ៧០.០០០ រៀល ក្នុងមួយខែ ។

**មាត្រា ២.-** សំរាប់ឆ្នាំថវិកា ២០០២ ត្រូវបានអនុញ្ញាតអោយផ្ទេរថវិការដ្ឋសំរាប់ឧបត្ថម្ភ តុល្យភាពភូមិ ឃុំ ដែលបានគ្រោងផ្តល់អោយថវិកាខេត្ត ក្រុង ចូលគណនីមូលនិធិឃុំ សង្កាត់ នៅរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ប្រាក់បំណាច់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣.–** ប្រាក់បំណាច់របស់ប្រធានក្រុមប្រឹក្សា និងជាមេឃុំ ចៅសង្កាត់ ជំទប់ទី១ ជំទប់ទី២ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀត ត្រូវចាប់អនុវត្តក្រោយពីមានប្រកាសទទួលស្គាល់ជាផ្លូវការរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៤.–** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.–** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី

**ស ខេង** — សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**យូ ហុកគ្រី**

**គាត ឈន់** — រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*